# ការស្វែងយល់អំពីការធានាឥណទាន

## ការស្វែងយល់អំពីនីតិវិធីសងត្រឡប់នៃកម្ចីដែលមានការធានារបស់ CGCC

ដោយៈ លោក ណូ លីដា អគ្គនាយករង



គោលការណ៍១ នៃគោលការណ៍ទាំង១៦ របស់ធនាគារពិភពលោក អំពីគម្រោងធានាឥណទានសាធារណៈចែងថា៖ **“ដំណើរការនៃការគ្រប់គ្រងការសងត្រឡប់ គួរតែមានប្រសិទ្ធភាព, កំណត់ច្បាស់លាស់ជាលាយលក្ខណ៍អក្សរ, មានតម្លាភាព, មានការលើកទឹកចិត្តដល់ការទារមកវិញនូវកម្ចីដែលបានបាត់បង់, និងសមស្របតាមក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសសាមុី”**។ ពិតណាស់ការគ្រប់គ្រងនីតិវិធីការសងត្រឡប់ គឺជាកត្តាកំណត់មួយនៃគណនេយ្យភាពរបស់ CGCC។ នីតិវិធីនៃការសងត្រឡប់ត្រូវបានចែងជាលាយលក្ខណ៍អក្សរនៅក្នុង កិច្ចព្រមព្រៀងធានាឥណទានដែលមានចំណងផ្លូវច្បាប់រវាង CGCC និងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFI) នីមួយៗដែលជាដៃគូរបស់ CGCC។



### ការដាក់ពាក្យស្នើសុំការសងត្រឡប់

ដើម្បីអាចដាក់ពាក្យស្នើសុំការសងត្រឡប់ពី CGCC លើកម្ចីដែលមានការធានាទាមទារនូវ ការបំពេញបាននូវលក្ខខណ្ឌដូចខាងក្រោម៖

- កម្ចីត្រូវបានចាត់ទុកថា “បាត់បង់” ដោយផ្អែកតាមនិយមន័យរបស់ធនាគារជាតិនៃកម្ពុជា។
- PFI បានទាមទារជាផ្លូវការនូវសំណងពីអ្នកខ្ចី ស្របតាមនីតិវិធីជាធរមានរបស់ PFIs។
- PFI បានអនុវត្តរាល់ដំណើរការក្នុងការទាមទារសំណងពីអ្នកខ្ចី ស្របតាមនីតិវិធីជាធរមានរបស់ PFI។
- នីតិវិធីផ្លូវច្បាប់ត្រូវបានចាប់ផ្តើមចំពោះអ្នកខ្ចី និងចំពោះទ្រព្យបញ្ចាំដែលមាន។
- កម្ចីដែលបាត់បង់ នោះត្រូវបានធ្វើសំវិធានធន ឬត្រូវបានលុបចោលដោយ PFI។

PFI ត្រូវដាក់ពាក្យស្នើសុំការសងត្រឡប់ពី CGCC ក្នុងរយៈពេលយ៉ាងយូរ ៩០ថ្ងៃ បន្ទាប់ពីលក្ខខណ្ឌនៃការសងត្រឡប់ខាងលើត្រូវបានបំពេញ។

## ការទូទាត់ការសងត្រឡប់

CGCC ទូទាត់ការសងត្រឡប់ជូន PFI ចំពោះកម្ចីដែលមានការធានាជា ២ដំណាក់កាល។ ក្នុងដំណាក់កាលទី១ CGCC នឹងទូទាត់ការសងត្រឡប់ចំនួន៥០% នៃទំហំសងត្រឡប់សរុបជូនទៅ PFIs យ៉ាងយូរ៣០ថ្ងៃ បន្ទាប់ពីទទួលបានសំណើសុំការសងត្រឡប់ ពី PFIs។ CGCC នឹងទូទាត់ការសងត្រឡប់ដែលនៅសេសសល់ ក្នុងដំណាក់កាលទី២ យ៉ាងយូរ ២ឆ្នាំបន្ទាប់ពីដំណាក់កាលទី១។ រយៈពេលយ៉ាងយូរ ២ឆ្នាំនេះគឺជាការទុកពេលជូន PFI ដើម្បីបន្តអនុវត្តនីតិវិធីទាមទារការសងត្រឡប់ពីអ្នកខ្ចីមកវិញ។ ទោះបីជាកម្ចីមានការធានាពី CGCC ក៏ដោយ PFI ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការទាមទារសំណងពីអ្នកខ្ចី ដូចករណីកម្ចីគ្មានការធានាពី CGCC ដែរ។

## ការទទួលបានសំណងមកវិញពីអ្នកខ្ចី

រាល់ការប្រមូលបានមកវិញនូវកម្ចី ដែលបានបាត់បង់ត្រូវបានបែងចែករវាង CGCC និង PFI ទៅតាមសមាមាត្រនៃការធានា។ PFI អាចប្រើប្រាស់សំណងដែលប្រមូលមកវិញពីអ្នកខ្ចី ដើម្បីទូទាត់ចំណាយពាក់ព័ន្ធទៅតាមលំដាប់អាទិភាពដូចខាងក្រោម៖

- ចំណាយពាក់ព័ន្ធនឹងដំណើរការ នៃការទាមទារការសងត្រឡប់
- ការប្រាក់សម្រាប់កម្ចីដែលមានការធានា ដែលអ្នកខ្ចីត្រូវបង់ជូន PFI
- ចំណែករបស់ CGCC ទៅតាមសមាមាត្រនៃការធានា
- ការផាកពិន័យនានាដែលអ្នកខ្ចីត្រូវបង់ជូន PFI

## សេណារីយ៉ូនៃការសងត្រឡប់ លើកទី១

ដើម្បីងាយយល់អំពីនីតិវិធីសងត្រឡប់របស់ CGCC ឧទាហរណ៍ថា CGCC ផ្តល់ការធានា ៨០% នៃប្រាក់ដើមលើកម្ចី “ក” ដែលមានទំហំ ១៥០.០០០ដុល្លារ និងមានរយៈពេលធានា ៧ឆ្នាំ។ ប្រសិនកម្ចី “ក” បាត់បង់ ហើយប្រាក់ដើមនៃកម្ចីដែលបានបាត់បង់មានចំនួន ១០០.០០០ដុល្លារ។ ដូច្នេះ CGCC ត្រូវសងត្រឡប់ដល់ PFI ចំនួន ៨០.០០០ដុល្លារ (៨០% នៃ ១០០.០០០ដុល្លារ) ដែលចែកចេញជា២ដំណាក់កាលដូចខាងក្រោម៖

| | | |
|---|---|---|
| ដំណាក់កាលទី១ | ៤០.០០០ ដុល្លារ | ៣០ថ្ងៃ ក្រោយពេលទទួលបានការស្នើសុំសងត្រឡប់ត្រឹមត្រូវពី PFI |
| ដំណាក់កាលទី២ | ៤០.០០០ ដុល្លារ | យ៉ាងយូរ ២ឆ្នាំ បន្ទាប់ពីដំណាក់កាលទី១ |

សន្មតថា PFI បានទាមទារសំណងពីអ្នកខ្ចីមកវិញសម្រាប់កម្ចី “ក” បន្ទាប់ពីទទួលបានសំណងពី CGCCដោយចំណាយពាក់ព័ន្ធនឹងដំណើរការនៃការទាមទារសំណងនេះ មានចំនួន ៥.០០០ដុល្លារ ហើយការប្រាក់ដែលអ្នកខ្ចីត្រូវបង់ជូន PFI មានចំនួន ៨០០ដុល្លារ។



## សេណារីយ៉ូទី១ នៃការសងត្រឡប់លើកទី២

ឧទាហរណ៍ សំណងដែល PFI បានទាមទារពីអ្នកខ្ចីមកវិញ មានចំនួន ៥.៥០០ដុល្លារ ក្រោយទទួលបានសំណងលើកទី១ ពី CGCC។ ករណីនេះ CGCC នឹងទូទាត់សំណងលើកទី២ ជូន PFI ដូចខាងក្រោម៖

| | | |
|---|---|---|
| សំណងទាមទារបានពីអ្នកខ្ចី | ៥.៥០០ | |
| ចំណាយពាក់ព័ន្ធនឹងដំណើរការនៃការទាមទារសំណង | (៥.០០០) | |
| ការប្រាក់ដែលអ្នកខ្ចីត្រូវបង់ជូន **PFI** | (៥០០) | |
| សំណងទាមទារបានពីអ្នកខ្ចី ដែលនៅសល់ | | 0 |
| ចំណែកដែលត្រូវបែងចែកឱ្យ **CGCC** | | 0 |
| សំណងលើកទី២ ដែល **CGCC** ត្រូវបង់ជូន **PFI** | | ៤០.០០០ |

នៅក្នុងសេណារីយ៉ូទី១ សំណងដែល PFI បានទាមទារត្រឡប់មកវិញពីអ្នកខ្ចី បន្ទាប់ពីទូទាត់ចំណាយពាក់ព័ន្ធនិងការប្រាក់រួចគឺ មិនមានសេសសល់ដើម្បីកាត់កងជាមួយ CGCC នោះទេ។ ដូច្នេះ CGCC មានកាតព្វកិច្ចទូទាត់សំណងលើកទី២ ជូន PFI តាម ចំនួនសំណងលើកទី២ ដែលត្រូវបង់គឺ ៤០.០០០ដុល្លារ។

## សេណារីយ៉ូទី២ នៃការសងត្រឡប់លើកទី២

ឧទាហរណ៍ PFI ទាមទារសំណងពីអ្នកខ្ចីបានចំនួន ៥០.០០០ដុល្លារ ក្រោយទទួលបានសំណងលើកទី១ ពី CGCC ករណីនេះ CGCC នឹងទូទាត់សំណងលើកទី២ ជូន PFI ដូចខាងក្រោម៖

| | | |
|---|---|---|
| សំណងទាមទារបានពីអ្នកខ្ចី | ៥០.០០០ | |
| ចំណាយពាក់ព័ន្ធនឹងដំណើរការនៃការទាមទារសំណង | (៥.០០០) | |
| ការប្រាក់ដែលអ្នកខ្ចីត្រូវបង់ជូន PFI | (៥០០) | |
| សំណងទាមទារបានពីអ្នកខ្ចី ដែលនៅសល់ | | ៤៤.២០០ |
| ចំណែកដែលត្រូវបែងចែកឱ្យ CGCC | | ៣៥.៣៦០ |
| សំណងលើកទី២ ដែល **CGCC** ត្រូវបង់ជូន **PFI** | | ៤.៦៤០ |

នៅក្នុងសេណារីយ៉ូទី២ សំណងដែល PFI បានទាមទារត្រឡប់មកវិញពីអ្នកខ្ចី បន្ទាប់ពីទូទាត់ចំណាយពាក់ព័ន្ធនិងការប្រាក់រួចគឺ នៅសល់ ៤៤.២០០ដុល្លារ ដែលត្រូវចែករំលែកមក CGCC ចំនួន ៨០% ស្មើ ៣៥.៣៦០ ដុល្លារ។ ប៉ុន្តែ CGCC មានកាតព្វកិច្ច បង់សំណងលើកទី២ ជូន PFI ចំនួន ៤០.០០០ដុល្លារ។ ដូច្នេះសំណងលើកទី២ ដែល CGCC ត្រូវបង់ជូន PFI មានចំនួន ៤.៦៤០ ដុល្លារ (៤០.០០០ ដក ៣៥.៣៦០)។

## សេណារីយ៉ូទី៣ នៃការសងត្រឡប់លើកទី២

ឧទាហរណ៍ PFI ទាមទារសំណងពីអ្នកខ្ចី បានចំនួន ៩០.០០០ដុល្លារ ក្រោយទទួលបានសំណងលើកទី១ ពី CGCC ករណីនេះ CGCC នឹងទូទាត់សំណងលើកទី២ ជូន PFI ដូចខាង៖

| | | |
|---|---|---|
| សំណងទាមទារបានពីអ្នកខ្ចី | ៩០.០០០ | |
| ចំណាយពាក់ព័ន្ធនឹងដំណើរការនៃការទាមទារសំណង | (៥.០០០) | |
| ការប្រាក់ដែលអ្នកខ្ចីត្រូវបង់ជូន PFI | (៨០០) | |
| សំណងទាមទារបានពីអ្នកខ្ចី ដែលនៅសល់ | | ៨៤.២០០ |
| ចំណែកដែលត្រូវបែងចែកឱ្យ CGCC | | ៦៧.៣៦០ |
| សំណងលើកទី២ ដែល **CGCC** ត្រូវបង់ជូន **PFI** | | (២៧.៣៦០) |

នៅក្នុងសេណារីយ៉ូទី២ សំណងដែល PFI បានទាមទារត្រឡប់មកវិញពីអ្នកខ្ចី បន្ទាប់ពីទូទាត់ចំណាយពាក់ព័ន្ធ និងការប្រាក់រួច គឺនៅសល់ ៨៤.២០០ដុល្លារ ដែលត្រូវចែករំលែកមក CGCC ចំនួន ៨០% ស្មើ ៦៧.៣៦០ ដុល្លារ។ ប៉ុន្តែ CGCC មានកាតព្វកិច្ចបង់សំណងលើកទី២ជូន PFI ចំនួន ៤០.០០០ ដុល្លារ។ ដូច្នេះ PFI ត្រូវទូទាត់មកឱ្យ CGCC វិញចំនួន ២៧.៣៦០ ដុល្លារ (៦៧.៣៦០ ដក ៤០.០០០)។

## សេណារីយ៉ូទី៤ នៃការសងត្រឡប់លើកទី២

ឧទាហរណ៍ PFI ទាមទារសំណងពីអ្នកខ្ចី បានចំនួន ៩០.០០០ដុល្លារ ក្រោយទទួលបានសំណងលើកទី២ ពី CGCC ករណីនេះ ការទូទាត់សំណងមានដូចខាងក្រោម៖

| | | |
|---|---|---|
| សំណងលើកទី១ និងលើកទី២ ដែល CGCC បានបង់ជូន PFI | | ៨០.០០០ |
| សំណងទាមទារបានពីអ្នកខ្ចី | ៩០.០០០ | |
| ចំណាយពាក់ព័ន្ធនឹងដំណើរការនៃការទាមទារសំណង | (៥.០០០) | |
| ការប្រាក់ដែលអ្នកខ្ចីត្រូវបង់ជូន PFI | (៨០០) | |
| សំណងទាមទារបានពីអ្នកខ្ចី ដែលនៅសល់ | | ៨៤.២០០ |
| ចំណែកដែលត្រូវបែងចែកឱ្យ **CGCC** | | ៦៧.៣៦០ |

នៅក្នុងសេណារីយ៉ូទី៤ CGCC បានបំពេញកាតព្វកិច្ចទូទាត់សំណងទាំងអស់ជូន PFI រួចរាល់។ បន្ទាប់មក PFI បានទាមទារសំណងត្រឡប់មកវិញពីអ្នកខ្ចីចំនួន ៩០.០០០ដុល្លារ ដោយក្រោយពេលទូទាត់ចំណាយពាក់ព័ន្ធ និងការប្រាក់រួច គឺនៅសល់ ៨៤.២០០ដុល្លារ។ ដូច្នេះ PFI ត្រូវទូទាត់ត្រឡប់មក CGCC វិញចំនួន ៨០% ស្មើនឹង ៦៧.៣៦០ ដុល្លារ។

CGCC គឺជាស្ថាប័នផ្តល់ការធានាឥណទានសាធារណៈថ្មីដែលមិនទាន់មានបទពិសោធន៍ក្នុងការទូទាត់សំណងលើកម្ចីដែលមានការធានានៅឡើយទេ។ ដូច្នេះ នីតិវិធីនៃការសងត្រឡប់របស់ CGCC អាចនឹងត្រូវបានកែសម្រួលតាមការចាំបាច់ ដើម្បីបង្កើនទំនុកចិត្ត និងគណនេយ្យភាពរបស់ CGCC។ តាមការពន្យល់ខាងលើ ទោះបីមានការធានាឥណទានពី CGCC ក៏ដោយ អ្នកខ្ចីនៅតែមានកាតព្វកិច្ចសងបំណុលទៅកាន់ PFI ហើយ PFI នៅតែមានកាតព្វកិច្ចបន្តទាមទារសំណងពីអ្នកខ្ចី។ តាមរយៈយន្តការធានាឥណទាននេះ ចំណែកនៃកម្ចីដែលត្រូវបានធានាដោយ CGCC គឺជាហានិភ័យឥណទានដែល CGCC ចែករំលែកពី PFI។